មើលវីដេអូ ចេតសិកនិងចិត្ត ភាគទី ៦

# ៧ - មនសិការចេតសិក (Attention)

មនសិការចេតសិក ជាធម្មជាតិនាំសម្បយុត្តធម៌ ទៅកាន់ អារម្មណ៍។

ករណំ ការោ មនស្មឹ ការោ = មនសិការោ ការធ្វើ ឈ្មោះថា ការៈ។

ការធ្វើទុកក្នុងចិត្ត ឈ្មោះថា មនសិការៈ។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# លក្ខណាទិចតុក្កៈរបស់មនសិការៈ

១ - សារណលក្ខណោ មានការធ្វើឲ្យសម្បយុត្តធម៌ត្រាច់ទៅជាលក្ខណៈ

២ - សម្បយុត្តានំ អារម្មណេ សំយោជនរសោ មានការញ៉ាំងសម្បយុត្តធម៌ ឲ្យប្រកបក្នុងអារម្មណ៍ ជាកិច្ច

៣ - អារម្មណាភិមុខីភាវបច្ចុប្បដ្ឋានោ មានការធ្វើឲ្យសម្បយុត្តធម៌តម្រង់មុខឆ្ពោះទៅទល់នឹងអារម្មណ៍ជាអាការប្រាកដ *(ដូចនាយសារថីនាំសេះឲ្យទៅកាន់ទិសដែលត្រូវការ)*

៤ - អារម្មណបទដ្ឋានោ មានអារម្មណ៍ ជាហេតុជិត។

# ចេតនា និងមនសិការចេតសិក (Attention)

ចេតសិកទាំង២នេះ មានសភាពស្រដៀងគ្នា ប៉ុន្តែមិនដូចគ្នាទេ។ ចេតនា មានតួនាទីតាក់តែងដាស់តឿនសម្បយុត្តធម៌ដែលកើតព្រមនឹងខ្លួន ឲ្យធ្វើកិច្ចរបស់ខ្លួន។ ចំណែកមនសិការចេតសិក មានតួនាទីប្រាថ្នានាំសម្បយុត្តធម៌ដែលកើតព្រមនឹងខ្លួនឲ្យប្រព្រឹត្តទៅ។

ចេតសិកទាំង ៧ នេះ ប្រកបជាមួយនឹងចិត្តគ្រប់ដួង ព្រោះសភាពរបស់ចិត្តនោះ កើតឡើងដើម្បី ដឹងអារម្មណ៍, ការដែលនឹងដឹងអារម្មណ៍បានព្រោះ ៖

- ផស្សៈ ធ្វើកិច្ចប៉ះខ្ទប់អារម្មណ៍
- វេទនា ជាសភាពសោយអារម្មណ៍
- សញ្ញា ធ្វើកិច្ចចាំអារម្មណ៍
- ចេតនា ធ្វើកិច្ចខ្វល់ខ្វាយឲ្យសម្រេច ឬជាស់តឿន
- ឯកគ្គតា ធ្វើសម្បយុត្តធម៌ដែលកើតព្រមគ្នាឲ្យ តាំងនៅក្នុងអារម្មណ៍តែមួយ
- ជីវិតិន្ទ្រិយ ជាធម៌រក្សាសម្បយុត្តធម៌ឲ្យប្រព្រឹត្តទៅ
- មនសិការៈ ការនាំសម្បយុត្តធម៌ ទៅកាន់អារម្មណ៍

** បើចេតសិកទាំង ៧ នេះ មិនកើតទេ ចិត្តក៏មិនអាចកើតបានដែរ ដូច្នេះ ចេតសិកទាំង ៧ នេះ ទើបមានឈ្មោះថា សព្វចិត្តសាធារណចេតសិក។*

# ចែកសព្វចិត្តសាធារណចេតសិក ៧ ដោយន័យផ្សេងៗគ្នា

**១ - ដោយខន្ធ** វេទនាចេតសិក ជាវេទនាខន្ធ សញ្ញាចេតសិក ជាសញ្ញាខន្ធ ចេតសិក ៥ ទៀត ជាសង្ខារក្ខន្ធ។

**២ - ដោយជាតិ** ចេតសិក ៦ *(វៀរវេទនា)* ជាជាតិទាំង ៤។ សុខ ទុក្ខ ជាវិបាកជាតិ ទោមនស្ស ជាអកុសលជាតិ សោមនស្សឧបេក្ខា ជាជាតិទាំង ៤។

**៣ - ដោយទ្វារ** ចេតសិក ៦ *(វៀរវេទនា)* កើតបាន ទ្វារ ៦ និងទ្វារវិមុត្ត។ សុខ ទុក្ខ កើតតាមកាយទ្វារ ទោមនស្ស កើតតាមទ្វារ ៦ សោមនស្ស ឧបេក្ខា កើតតាមទ្វារ ៦ និងទ្វារវិមុត្ត។

៤ - ដោយអារម្មណ៍

ចេតសិក ៦ *(វៀរវេទនា)* ដឹងអារម្មណ៍បាន ៦។ សុខ ទុក្ខ ដឹងផោដ្ឋព្វារម្មណ៍ ទោមនស្ស ដឹងអារម្មណ៍បាន ៦ សោមនស្ស ឧបេក្ខា ដឹងអារម្មណ៍បាន ៦ *(គ្រប់ទាំងអស់)*

៥ - ដោយភូមិ

ចេតសិក ៦ *(វៀរវេទនា)* ប្រព្រឹត្តទៅក្នុងភូមិទាំង ៤ *(កើតក្នុងភូមិ៣០)*។ សុខ ទុក្ខ ទោមនស្ស ជាកាមភូមិ *(កើតក្នុងកាមភូមិ ១១)* សោមនស្ស ជាកាមភូមិ រូបភូមិ លោកុត្តរភូមិ *(កើតក្នុងភូមិ ៣០)* ឧបេក្ខា ជាភូមិទាំង ៤ *(កើតក្នុងភូមិ ៣០ វៀរអសញ្ញីភូមិ)*

៦ - ដោយវត្ថុ

ចេតសិក ៦ *(វៀរវេទនា)* កើតអាស្រ័យវត្ថុទាំង ៦ សុខ ទុក្ខ កើតត្រង់កាយវត្ថុ ទោមនស្ស សោមនស្ស កើតត្រង់ហទយវត្ថុ ឧបេក្ខា កើតបានត្រង់វត្ថុ ៥ *(វៀរកាយវត្ថុ)*

៧ - ដោយហេតុ

ចេតសិក ៧ ជានហេតុ

៨ - ដោយសោភណ

ចេតសិក ៧ ជាសោភណក៏មាន អសោភណក៏មាន

៩ - ដោយលោក

ចេតសិក ៧ ជាលោកិយក៏មាន លោកុត្តរក៏មាន។